នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 06-Jan-2015, 15:34
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៥ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យដោះស្រាយចំពោះវិការៈនៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន**

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះតុលាការកំពូល:
ចៅក្រម គង់ ស្រឹម, ប្រធាន
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម C. N. JAYASINGHE
ចៅក្រម ម៉ុង មុនីចរិយា
ចៅក្រម Florence Ndepele MUMBA
ចៅក្រម យ៉ា ណារិន

**ចម្លងជូន:**

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

ជនជាប់ចោទ:
នួន ជា
ខៀវ សំផន

មេធាវីការពារក្ដីជនជាប់ចោទ:
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Arthur VERCKEN

# សំណើ

1. នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាបានទទួលដំណឹងអំពីការដាក់បណ្ដឹងសាទុក្ខ (“សេចក្ដីជូនដំណឹង”) របស់មេធាវីការពារក្ដី ខៀវ សំផន (“មេធាវីការពារក្ដី”) ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០១ (“សាលក្រម”)[1] ដែលនៅក្នុងសាលក្រមនោះ មេធាវីការពារក្ដីបានរៀបរាប់ទទ្ទឹករណ៍ចំនួន១៥២ សម្រាប់បណ្ដឹងសាទុក្ខ។

2. នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ខៀវ សំផន បានដាក់សារណាបណ្ដឹងសាទុក្ខរបស់គាត់ (“បណ្ដឹងសាទុក្ខ”) ជូនទៅអង្គជំនុំជម្រះតុលាការកំពូល (“អង្គជំនុំជម្រះ”)។ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ គឺពីរ(០២)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទកំណត់ដែលអង្គជំនុំជម្រះបានសម្រេច[2] ត្រូវបានកន្លងផុតទៅ ខៀវ សំផន បានដាក់សំណៅកែតម្រូវមួយ ដោយបានបញ្ជាក់ថា កំណែតម្រូវទាំងនោះគឺសុទ្ធតែជាបញ្ហានៃទម្រង់បែបបទទាំងអស់ ហើយមិនមែនជាបញ្ហាផ្នែកខ្លឹមសារទេ[3]។ ខណៈដែលសហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា កថាខណ្ឌសំខាន់ថ្មីៗចំនួនបួន(០៤) ត្រូវបានដាក់បន្ថែមចូលទៅក្នុងសំណៅកែតម្រូវនៃបណ្ដឹងសាទុក្ខនោះ[4] ពួកគាត់ក៏ពុំមានការជំទាស់ណាមួយទៅកាន់អង្គជំនុំជម្រះតុលាការកំពូលដែរដែលបានទទួលយក “សំណៅកែតម្រូវ” របស់ ខៀវ សំផន ស្ដីពីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង០០២/០១។

3. យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាជូនសេចក្ដីសន្និដ្ឋានថា ដោយហេតុថាត្រូវបានកែតម្រូវនោះគឺមានវិការៈ។ ខណៈដែលសំណៅដើមនៃបណ្ដឹងសាទុក្ខនេះ រួមមាន សេចក្ដីយោងចំនួន១៤៧ នៅក្នុងតួសេចក្ដីនៃបណ្ដឹងសាទុក្ខ ដែលទំនងជាត្រូវបានយោងទៅដល់ទទ្ទឹករណ៍នានា នៃបណ្ដឹងសាទុក្ខនេះ ដែលបានរៀបរាប់នៅក្នុងសេចក្ដីជូនដំណឹងមួយដែលមានអំណះអំណាងនានា តាមក្រោយនោះ សេចក្ដីយោងទាំងនេះត្រូវបានដកចេញពីសំណៅកែតម្រូវនៃបណ្ដឹងសាទុក្ខ។ ការដាក់លេខកថាខណ្ឌនៅលើសំណៅកែតម្រូវ ក៏ខុសគ្នាទៅនឹងសំណៅដើមផងដែរ។ ដូច្នេះ មិនច្បាស់លាស់ទេថា តើអំណះអំណាងមួយណាដែលទាក់ទងទៅនឹងទទ្ទឹករណ៍ណាមួយនៃបណ្ដឹងសាទុក្ខ

---

[1] **E313/2/1** សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីលោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមលើសំណុំរឿង០០២/០១, ២៩ កញ្ញា ២០១៤។

[2] **F9** សេចក្ដីសម្រេចលើសំណើសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់សារណាបណ្ដឹងសាទុក្ខ និងសារណាតប, ៣១ តុលា ២០១៤។

[3] **F17/Corr. 1** Mémoire d’appel de la Défense de M.KHIEU Samphân contre le jugement rendu dans le procès 002/01, ៣១ ធ្នូ ២០១៤ ត្រង់ FR 01052205។

[4] *ដដែលដូចខាងលើ*, ត្រង់កថាខណ្ឌ៦៩-៧៣។

ហើយថាតើគ្រប់ទទ្បីករណ៍ទាំងអស់នៃបណ្តឹងសាទុក្ខ ឬមួយយ៉ាងណា ដែលត្រូវបានគ្របដណ្តប់ ឬមួយក៏មានទទ្បីករណ៍ខ្លះត្រូវបានបោះបង់ចោល។

4. សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា ដោយយោងទៅតាមវិធាននីតិវិធីអន្តរជាតិ គោលបំណង នៃសេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខគឺ "ដើម្បីឱ្យអ្នកឆ្លើយតបធ្វើការផ្តោតការយកចិត្តទុកដាក់ ចាប់តាំងពីថ្ងៃដែលសេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខត្រូវបានដាក់ជូនភ្លាម គឺត្រូវផ្តោតលើអំណះ អំណាងដែលនឹងត្រូវបានបង្កើតឡើងនៅក្នុងសារណាបណ្តឹងសាទុក្ខ នៅពេលក្រោយមក" ក៏ដូចជា "ដើម្បីផ្តល់នូវសេចក្តីពិស្តារនៃអំណះអំណាងទាំងឡាយដែលភាគីនានាមានបំណងនឹងធ្វើការលើក ឡើងដើម្បីគាំទ្រដល់ទទ្បីករណ៍នានានៃបណ្តឹងសាទុក្ខ"[5]ផងដែរ។ តាមរយៈការបង្ហាញយន្តការ សម្រាប់សេចក្តីណែនាំអនុវត្តរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិស្តីពីលក្ខខណ្ឌតម្រូវ និងនីតិវិធី សម្រាប់បណ្តឹងសាទុក្ខ ចែងថាទទ្បីករណីនៃបណ្តឹងសាទុក្ខ និងអំណះអំណាងផ្សេងៗ ត្រូវតែ កំណត់ និងដាក់លេខតាមលំដាប់ដូចគ្នានឹងសេចក្តីជូនដំណឹងបណ្តឹងសាទុក្ខរបស់អ្នកដាក់បណ្តឹង សាទុក្ខដែរ វៀរលែងតែខុសគ្នាផ្សេងពីនេះ ដែលទទួលបានការអនុញ្ញាតពីអង្គជំនុំជម្រះសាលា ឧទ្ធរណ៍។ ដើម្បីឱ្យស្របនឹងការអនុវត្តជាអន្តរជាតិ មេធាវីការពារក្តី នួន ជា បានស្វែងរកការធ្វើ សហសម្ព័ន្ធខ្លឹមសារនៃសារណាបណ្តឹងសាទុក្ខរបស់ខ្លួន ជាមួយនឹងទទ្បីករណ៍ទាំងឡាយដែលបាន កំណត់នៅក្នុងសេចក្តីជូនដំណឹងបណ្តឹងសាទុក្ខរបស់ខ្លួនរួចហើយ[6]។ ជាងនេះទៅទៀត សារណា បណ្តឹងសាទុក្ខ មិនអាចមានអំណះអំណាងណាមួយដែលមិនមាននៅក្នុងសេចក្តីជូនដំណឹងបណ្តឹង សាទុក្ខនោះទេ។

5. ដូចបានដាក់ជូន បណ្តឹងសាទុក្ខដែលបានកែតម្រូវឡើងវិញមិនអាចឱ្យអង្គជំនុំជម្រះ និងភាគីធ្វើ សហសម្ព័ន្ធនៃខ្លឹមសាររបស់វា ទៅនឹងទទ្បីករណ៍ដែលមានបានដាក់លេខរួចហើយនៃបណ្តឹងសាទុក្ខ ក្នុងសេចក្តីជូនដំណឹងឡើយ។ គោលបំណឹងនៃតម្លាភាព ភាពគ្រប់គ្រាន់នៃការជូនដំណឹង និងភាព

[5] *Ferdinand Nahimana និងគូកន ទល់នឹង រដ្ឋអាជ្ញា,* សំណុំរឿងលេខ ICTR-99-52-A, សេចក្តីសម្រេចលើញត្តិរបស់ដើមបណ្តឹង សាទុក្ខឈ្មោះ Jean-Bosco Barayagwiza សុំការអនុញ្ញាតដាក់ជូនទទ្បីករណ៍បន្ថែមក្នុងបណ្តឹងសាទុក្ខ, សុំធ្វើវិសោធនកម្មលើសេចក្តី ជូនដំណឹងពីបណ្តឹងសាទុក្ខ និងសុំកែតម្រូវលើសារណារបស់ដើមបណ្តឹងសាទុក្ខ, ១៧ សីហា ២០០៦ ត្រង់កំណត់សម្គាល់ជើងទំព័រទី១៣៩, ដោយបានលើកឡើងពីករណីរឿង *រដ្ឋអាជ្ញា ទល់នឹង Ignace Bagilishema,* សំណុំរឿងលេខ ICTR-95-1A-A, សេចក្តីសម្រេចលើ ញត្តិស្នើសុំឱ្យធ្វើការប្រកាសថាសេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញា គឺមិនអាចទទួលយកបានទេ, ២៦ តុលា ២០០១ ត្រង់ទំព័រ៣។

[6] សេចក្តីណែនាំអនុវត្តស្តីពីលក្ខខណ្ឌតម្រូវ និងនីតិវិធីសម្រាប់បណ្តឹងសាទុក្ខ, ៦ សីហា ២០១៣ (សេចក្តីណែនាំអនុវត្ត MICT/10), កថាខណ្ឌ(គ)(៥)។ សូមមើលផងដែរ បទបញ្ជាលេខ៥៧-៥៩ នៃ*បទបញ្ជារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ,* ICC-BD/01-03-11 (ចូលជាធរមានចំពោះច្បាប់វិសោធនកម្ម ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២)។

ត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី នឹងត្រូវអន់ថយជាខ្លាំងដោយសារតែកង្វះសហាសម្ព័ន្ធដូច្នេះ។ នៅក្នុងករណីជាច្រើន ធ្វើឲ្យសហព្រះរាជអាជ្ញាមិនប្រាកដអំពីអ្វីជាបណ្តឹងដែលសហព្រះរាជត្រូវឆ្លើយតប ហើយក៏អាចបង្កឲ្យមានមន្ទិលសង្ស័យខ្លះចំពោះអង្គជំនុំជម្រះតុលាការកំពូលអំពី ថាតើអំណះអំណាងណាខ្លះដែលបានធ្វើ ដើម្បីគាំទ្រចំពោះទឡ្ហីករណ៍ណាមួយនៃបណ្តឹងសាទុក្ខ និងថាតើទឡ្ហីករណ៍ណាដែលត្រូវបានបោះបង់ចោល ប្រសិនបើមាន។

អាស្រ័យមូលហេតុដូចបានរៀបរាប់ខាងលើ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះ ៖

(ក) **ទទួលយក** "ច្បាប់ត្រឹមត្រូវ" នៃបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ដែលបានដាក់ពីរថ្ងៃក្រោយថ្ងៃផុតកំណត់ និងដកចេញចំណុចមន្ទិលសង្ស័យណាមួយដែលនាំឲ្យភាគីយល់ច្រឡំថា ភាគីគួរត្រូវឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខនេះ។

(ខ) **បង្គាប់ឲ្យ** មេធាវីការពារក្តីដាក់នៅក្នុងរយៈពេលមួយសមស្រប នូវឯកសារបន្ថែមទៅនឹងបណ្តឹងសាទុក្ខនេះ ដោយបញ្ជាក់ពីកថាខណ្ឌទាំងឡាយណានៃច្បាប់ត្រឹមត្រូវនេះ មានការពាក់ព័ន្ធនឹងទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខដែលមាននៅក្នុងសេចក្តីជូនដំណឹងរបស់ពួកគាត់៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី៦ ខែមករា ឆ្នាំ២០១៥ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | |